# ក្រសួងបរិស្ថាន និងអង្គការWWF សហរៀបចំដំណើរទស្សនកិច្ចសារព័ត៌មានទៅកាន់តំបន់ព្រៃលិចទឹកមេគង្គ

អ្នកសារព័ត៌មានសរុបចំនួនសាមសិបនាក់ មកពីបណ្តាញសារព័ត៌មានចំនួន ១៧ នឹងចូលរួមក្នុងដំណើរទស្សនកិច្ចសារព័ត៌មានរយៈពេលពីរថ្ងៃ ទៅតំបន់ព្រៃលិចទឹកទន្លេមេគង្គក្នុងខេត្តក្រចេះ ចាប់ពីថ្ងៃទី ១៦-១៧ ខែមិថុនា ឆ្នាំ ២០២២ ដែលសហរៀបចំឡើងដោយក្រសួងបរិស្ថាន និងអង្គការWWF។ **ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋលេខាធិការនិងជាអ្នកនាំពាក្យក្រសួងបរិស្ថាន** នឹងដឹកនាំដំណើរទស្សកិច្ចនេះ ក្នុងគោលបំណងផ្តល់ជូនអ្នកសារព័ត៌មាននូវឱកាសដើម្បីទទួលបានបទពិសោធន៍ផ្ទាល់ពីស្ថានភាពសត្វព្រៃនៅក្នុងតំបន់ និងស្វែងយល់ពីសក្តានុពលនៃតំបន់ព្រៃលិចទឹកមេគង្គសម្រាប់ការអភិរក្សធនធានជីវចម្រុះ និងការស្តារប្រភេទសត្វព្រៃសំខាន់ៗ ដែលមានតម្លៃជាសកល ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងជីវភាពសហគមន៍មូលដ្ឋាន។

មន្ត្រីមកពីក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តក្រចេះ សមាជិកសហគមន៍ **លោក សេង ទៀក នាយកអង្គការ** WWF និងបុគ្គលិកអង្គការWWF សរុបជាង៦០នាក់ក៏នឹងចូលរួមក្នុងដំណើរទស្សនកិច្ចនេះដែរ។

**ឯកឧត្តម នេត្រ ភក្ត្រា** បានឲ្យដឹងថា៖ «គោលបំណងនៃដំណើរទស្សនកិច្ចសារព័ត៌មាននេះ ធ្វើឡើងស្របតាមគោលការណ៍របស់ក្រសួងបរិស្ថាន ពោលគឺលើកកម្ពស់ និងបង្កើនការរាយការណ៍ព័ត៌មានប្រកបដោយវិជ្ជាជីវៈអំពីវិស័យបរិស្ថាន ធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះនៅកម្ពុជា។

**ឯកឧត្តម**មានប្រសាសន៍ថា៖ «ព័ត៌មានដែលប្រជាពលរដ្ឋទទួលបាន នឹងជួយបង្កើនចំណេះដឹងផ្នែកបរិស្ថានរបស់ពួកគាត់ និងរួមចំណែកបណ្តុះទឹកចិត្តស្រលាញ់ និងថែរក្សាបរិស្ថាន ធនធានធម្មជាតិ និងជីវៈចម្រុះ មិនត្រឹមតែប៉ុណ្ណោះអាចលើកទឹកចិត្តអោយពួកគាត់ធ្វើសកម្មភាពជាវិជ្ជមានក្នុងចូលរួមការការពារធនធានទាំងនេះសម្រាប់មនុស្សជំនាន់ក្រោយៗផងដែរ»។

នៅតំបន់ព្រៃលិចទឹកមេគង្គ ក្រសួងបរិស្ថាន និងអង្គការWWF បាននិងកំពុងធ្វើការយ៉ាងជិតស្និតជាមួយនឹងមន្ទីរពាក់ព័ន្ធ សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីរួមគ្នាការពារព្រៃឈើ ធនធានធម្មជាតិនិងសត្វព្រៃកំពុងរងគ្រោះថ្នាក់ជិតផុតពូជនៅតំបន់ការពារចំនួន០២ ដែលមានផ្ទៃដីសរុបប្រមាណ៦២ពាន់ហិកតា។ ដំណើរទស្សនកិច្ចសារព័ត៌មាននេះនឹងដឹកនាំអ្នកចូលរួមឲ្យស្វែងយល់ពីតម្លៃជាសកលនៃដែនជម្រកសត្វព្រៃព្រែកប្រសព្វដែលជាទីជម្រកនៃសត្វក្តាន់ ឈ្លូស ឆ្មាដាវ សំពោច និងដែនជម្រកសត្វព្រៃសំបូរដែលជាជម្រកសត្វរមាំង និងប្រភេទបក្សីសំខាន់ៗ ដូចជា ត្រយ៉ងយក្ស ត្រយ៉ងចម្កកស កុកពាក់អំបោះ ត្រដក់តូច ក្ងោក និងសត្វរំពេទន្លេដែលជាប្រភេទសត្វកម្របំផុតនៅតំបន់អាស៊ីអាគ្នេយ៍។

**លោក សេខ ឡៀក នាយកអង្គការ**WWF បានលើកឡើងសារៈសំខាន់នៃដំណើរទស្សនកិច្ចសារព័ត៌មាននេះ ថាជាការនាំផ្សារភ្ជាប់កាន់តែជិតស្និតនូវទំនាក់ទំនងរវាងសារព័ត៌មាន និងវិទ្យាសាស្ត្រ ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពនៃការផ្សព្វផ្សាយព័ត៌មានបែបអាជីពស្ដីអំពីកិច្ចការអភិរក្ស ដល់សាធារណៈជននិងអ្នកពាក់ព័ន្ធក្នុងវិស័យនេះ។

លោកថា៖ «ដំណើរទស្សនកិច្ចសារព័ត៌មាននាពេលនេះ នឹងផ្ដល់ដល់អ្នកសារព័ត៌មាននូវព័ត៌មានថ្មីដែលប្រកបដោយចំណេះដឹងផ្អែកលើវិទ្យាសាស្ត្រ ដែលអាចជួយពង្រីកទស្សនៈវិស័យរបស់អ្នកសារព័ត៌មានឲ្យកាន់តែប្រសើរឡើង បង្កើនការយល់ដឹងជាសាធារណៈអំពីតម្លៃដ៏វិសេសវិសាលឥតកាត់ថ្លៃបាននៃតំបន់ព្រៃលិចទឹកមេគង្គសម្រាប់ការអភិរក្សប្រភេទសត្វដែលកម្រៗនៅលើពិភពលោក និងតួនាទីនៃតំបន់នេះក្នុងការផ្គត់ផ្គង់នូវតម្រូវការចាំបាច់ជាច្រើនគាំទ្រដល់ប្រព័ន្ធទ្រទ្រង់ជីវិតសម្រាប់មនុស្ស និងសត្វ»។

ដំណើរទស្សនកិច្ចសារព័ត៌មាននេះ ជាផ្នែកមួយដ៏សំខាន់នៃការពង្រឹងទំនាក់ទំនងសាធារណៈដែលក្រសួងបរិស្ថាន និងអង្គការWWF បាន និងកំពុងលើកកម្ពស់។ ដោយផ្អែកលើមូលដ្ឋាននៃកិច្ចខិតខំប្រឹងប្រែងនេះ ក្រសួងបរិស្ថាន និងអង្គការWWF បាន និងកំពុងបន្តកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធក្នុងការគ្រប់គ្រង ស្ដារឡើងវិញ និងការពារធនធានធម្មជាតិ ប្រភេទសត្វព្រៃដែលមានតម្លៃជាសកលជាច្រើន ហើយស្របពេលជាមួយគ្នាដែរលើកទឹកចិត្ត និងសហការជាមួយសហគមន៍មូលដ្ឋានក្នុងការអភិរក្ស និងជួយពង្រឹងជីវភាពរស់នៅរបស់សហគមន៍ក្នុងគោលបំណងកៀរការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារប្រកបដោយនិរន្តរ៍ភាព។

ដែនជម្រកសត្វព្រៃព្រែកប្រសព្វមានផ្ទៃដីសរុប ១២,៧៧០ហិកតា ស្ថិតក្នុងស្រុកព្រែកប្រសព្វ។ ដែនជម្រកសត្វព្រៃសំបូរ មានផ្ទៃដីសរុប ៥០,០៩៣ហិកតា ស្ថិតក្នុងស្រុកសំបូរ ខេត្តក្រចេះ។ ដែនជម្រកសត្វព្រៃទាំងពីរនេះជាទីជម្រកធម្មជាតិយ៉ាងសំខាន់សម្រាប់ថនិកសត្វសរុបចំនួនប្រមាណ11ប្រភេទ ឧរង្គសត្វ និងពពួកល្មូនចំនួន56ប្រភេទ រុក្ខជាតិចំនួន683ប្រភេទ សត្វស្លាបជាង200ប្រភេទ និងត្រីចំនួន223ប្រភេទ។ លើសពីនេះ ធនធានអនុផលព្រៃឈើ និងទន្លេ ជាប្រភពធនធានយ៉ាងសំខាន់សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ និងសម្រាប់ការស្វែងរកចំណូលរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាផ្ដល់ប្រព័ន្ធគាំទ្រភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ទឹកជំនន់ និងគ្រោះរាំងស្ងួត។ យើងសូមថ្លែងអំណរគុណចំពោះការផ្ដល់មូលនិធិ និងការគាំទ្រពី WWFបែលហ្សិក រដ្ឋាភិបាលប្រទេសបែលហ្សិក (DGD) មូលនិធិភាពជាដៃគូប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (CEPF) ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចប្រតិបត្តិការ(SDC) និងBinco ។

-end-